២-ចម្លងសេចក្តីសម្រេច ផ្ញើទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ០៨-១៦៩០/៩៨ គជប ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៨ ទុកជាបានការពេញអង្គប្រជុំ ។

៣-សេចក្តីសម្រេចនេះធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៨ នាសវនាការ ជាសាធារណៈ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ដកស្រង់ត្រឹមត្រូវតាមច្បាប់ដើម

ហត្ថលេខា និងត្រា លេខាធិការ

**ចាន់ សុក** **ម៉េង គឹមលី**

★★★

# III- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យ លេខ ៥៩ អនក្រ.បក

### ស្តីពីការផ្ទេរឥណទាន

****

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤ /៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រឹត្យ ជស/រកត/០៨៩៧ /១៥៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញច្បាប់ស្តីពីការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤

-បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម /០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦

-បានឃើញច្បាប់ស្តីពីអំពីប្រពន្ធ័ហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយ ព្រះរាជក្រម ០១នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣

-បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខជស.រកម ០១៩៨/០១ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ១៩៩៨

www.pheakdeylaw.com

-បានឃើញអនុក្រឹត្យ លេខ០៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៨ របស់រាជរដ្ឋាភិបាល ស្ដីពីការបែងចែកឥណទានតាមជំពូក នៃច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨

-បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ០០៥ ប្រ.ក.សហវ.ថ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៩៨ ស្ដីពីការបែងចែកឥណទានផ្ទៃក្នុងជំពូក តាមប្រភេទ កថាខ័ណ្ឌ វាក្យខ័ណ្ឌ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨

-បានឃើញប្រកាសលេខ០១ ប្រ.ក.សហវ ចុះថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៩៨ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្ដីពីចំណាត់ថ្នាក់ ចំណូល និងចំណាយចរន្តតាមប្រភេទជំពូក ប្រភេទ កថាខ័ណ្ឌ វាក្យខ័ណ្ឌ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨

-តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**សំរេច**

មាត្រា១ .-ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ៨៥លានរៀល (ប៉ែតសិបប្រាំលានរៀល) ជំពូក១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងផ្គត់ផ្គង់សេវា ) មកជំពូក ៣១ (អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច និងវប្បធម៌) របស់ក្រសួងសុខាភិបាល សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨ ។

មាត្រា២ .- ឥណទានថវិកា ក្នុងមាត្រា១ខាងលើត្រូវបានអនុញ្ញាតិអោយប្រើប្រាស់សំរាប់បំពេញតំរូវការចំណាយឧបត្ថម្ភអ្នកជំងឺក្រីក្រ សំរាកព្យាបាលនៅមន្ទីរពេទ្យកាល់ម៉ែត្រ ។

មាត្រា៣ .- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

បានឡាយព្រះហស្ថលេខា និងត្រា

អ៊ឹង ហួត ហ៊ុន សែន

★★★

# អនុក្រឹត្យ លេខ ៦០ អនក្រ.បក

## ស្ដីពី

## ការផ្ដល់ឥណទានថវិកាបន្ថែម ចំនួន ១.១៦០ លានរៀល (មួយពាន់មួយរយហុកសិបលានរៀល) ទៅលើឥណទានថវិការបស់ក្រសួងមហាផ្ទៃ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨

* * * *

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

www.pheakdeylaw.com